ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ១១៥ ..... សហវ.ប្រក.

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨

# ប្រកាស

## ស្តីពី

## ការបង្កើត និង កិច្ចដំណើរការជើងសារគយ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រ កម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៧០៧ / ០១៧ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀប ចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

បុគ្គលដែលមាននីតិសម្បទា ដើម្បីបំពេញបែបបទសុំអាជ្ញាប័ណ្ណ មានដូចខាងក្រោម ៖



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sanrkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- អ្នកនាំចូល អ្នកនាំចេញ ម្ចាស់ទំនិញ ឬតំណាងមានការអនុញ្ញាត អាចធ្វើការបំពេញបែបបទគយតែលើទំនិញសម្រាប់អាជីវកម្មរបស់ខ្លួនផ្ទាល់

- បុគ្គលទាំងឡាយណា ដែលទទួលបានការអនុញ្ញាតជាជើងសារគយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការស្នើសុំរបស់នាយកទីចាត់ការគយ និងរដ្ឋាករ ស្របតាមបញ្ញត្តិប្រការ ៧ នៃប្រកាសនេះ អាចធ្វើការបំពេញបែបបទគយក្នុងនាមអ្នកដទៃ ។

**ប្រការ ២ .-**

នីតិបុគ្គល ឬរូបវន្តបុគ្គល ដែលទទួលបានការអនុញ្ញាតជាជើងសារគយ ត្រូវបានអនុញ្ញាតឱ្យតម្កល់ប្រតិវេទន៍គយ និងបំពេញទម្រង់ការគយក្នុងនាមអ្នកដទៃទៀតបានស្របតាមបញ្ញត្តិមាត្រា ៣៦ នៃច្បាប់ស្ដីពីគយ និងលក្ខខណ្ឌនានា ដែលមានចែងនៅក្នុងអាជ្ញាប័ណ្ណជើងសារគយ ដែលចេញដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៣ .-**

បុគ្គលណាមួយ រួមទាំងម្ចាស់ទំនិញ និងនិយោជិកនៃក្រុមហ៊ុន ឬអង្គការមួយ អាចបំពេញបែបបទគយសម្រាប់ខ្លួនផ្ទាល់ សម្រាប់ក្រុមហ៊ុន ឬសម្រាប់អង្គការរបស់ខ្លួន និងមិនត្រូវបានចាត់ទុកថា បានបំពេញវិជ្ជាជីវៈជាជើងសារគយឡើយ ។

និយោជិកទាំងឡាយរបស់អ្នកនាំចូល ឬអ្នកនាំចេញ ដែលមានបំណងបំពេញបែបបទគយក្នុងនាមក្រុមហ៊ុន ឬអង្គការរបស់ខ្លួន ត្រូវផ្ដល់ដល់មន្ត្រីគយមានសមត្ថកិច្ចនូវលិខិតអនុញ្ញាតជាលាយល័ក្ខអក្សរពីក្រុមហ៊ុន ឬអង្គការទាំងនោះ និងគម្រូហត្ថលេខាផងដែរ ។

អ្នកនាំចូល អ្នកនាំចេញ ឬម្ចាស់ទំនិញ ដែលមិនចង់ធ្វើធុរកិច្ចជាមួយគយដោយផ្ទាល់ត្រូវប្រើប្រាស់សេវាកម្មជើងសារគយ ។

ក្នុងកាលៈទេសៈដែលសេវាកម្មជើងសារគយពុំអាចរកបាន អ្នកនាំចូល អ្នកនាំចេញ ឬម្ចាស់ទំនិញ អាចសុំទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវការអនុញ្ញាតជាបណ្ដោះអាសន្ន ដើម្បីឱ្យបុគ្គលដែលមិនមែនជាជើងសារគយ អាច

បំពេញបែបបទតយបាន ក្នុងនាមអ្នកនាំចូល អ្នកនាំចេញ ឬម្ចាស់ទំនិញទាំងនេះ ។ ការអនុញ្ញាតជាពិសេសបែបនេះនឹងត្រូវផ្តល់ជូនសម្រាប់តែរយៈពេលកំណត់ និង សម្រាប់តែប្រតិបត្តិការពាក់ព័ន្ធនឹងទំនិញដោយឡែកមួយចំនួនប៉ុណ្ណោះ ។

**ប្រការ ៤ .-**

បុគ្គលណាមួយ មានបំណងបំពេញធុរកិច្ចជាជើងសារគយ ត្រូវតែមាន អាជ្ញាប័ណ្ណជើងសារគយ ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ពាក្យ សុំអាជ្ញាប័ណ្ណជើងសារគយត្រូវដាក់ស្នើសុំទៅនាយកទីចាត់ការគយ និងរដ្ឋាករតាម ទម្រង់ និងសេចក្តីណែនាំដែលកំណត់ដោយទីចាត់ការគយ និង រដ្ឋាករ ។

ពាក្យសុំអាជ្ញាប័ណ្ណជើងសារគយរួមមាន ៖

- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកស្នើសុំ ។ ក្នុងករណីជានីតិបុគ្គលត្រូវ បញ្ជាក់ឈ្មោះ និងអាសយដ្ឋានរបស់ថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធនានា

- ទីតាំងដែលធុរកិច្ចជើងសារគយត្រូវដំណើរការ

- ឈ្មោះរបស់ជើងសារគយដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងទីតាំង ដែលត្រូវធ្វើប្រតិបត្តិការ

- របាយការណ៍ហិរញ្ញវត្ថុ ដែលបង្ហាញថា អ្នកស្នើសុំមានធនធានហិរញ្ញវត្ថុ គ្រប់គ្រាន់ដើម្បីធ្វើធុរកិច្ចបាន

- លិខិតបញ្ជាក់ទោសដែលចេញដោយស្ថាប័នមានសមត្ថកិច្ច

- មានវិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម

- ឯកសារ និងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងអនុលោមភាព ។

**ប្រការ ៥ .-**

រូបវន្តបុគ្គលណាម្នាក់នឹងត្រូវចាត់ទុកថា ជាជើងសារគយ មានលក្ខណៈ សម្បត្តិគ្រប់គ្រាន់ក្រោមបញ្ញត្តិនៃប្រកាសនេះត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- មានសញ្ជាតិកម្ពុជា ឬជានិវេសនជនដែលមានលំនៅដ្ឋាននៅកម្ពុជា

- មានអាយុយ៉ាងតិច ១៨ ឆ្នាំ

- មានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬខ្ពស់ជាង

- មានលិខិតបញ្ជាក់ទោសដែលចេញដោយស្ថាប័នមានសមត្ថកិច្ច

- មានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីធ្វើធុរកិច្ច

- បានប្រឡងជាប់ ជាជើងសារគយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ក្រោមការរៀបចំ និងចាត់ចែងដោយទីចាត់ការគយ និងរដ្ឋាករ

- មានប្រវត្តិអនុលោមភាពសារពើពន្ធស្អាតស្អំ ។

**ប្រការ ៦ .-**

និតិបុគ្គលណាមួយ និងត្រូវចាត់ទុកថាជាជើងសារគយ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្រោមបញ្ញត្តិនៃប្រកាសនេះត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

១- ក្រុមហ៊ុនៈ

- ត្រូវបង្កើតជាក្រុមហ៊ុននិងមានចុះបញ្ជិកានៅក្រសួងពាណិជ្ជកម្ម
- មានធនធាន ហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីធ្វើធុរកិច្ច
- មានប្រវត្តិអនុលោមភាពសារពើពន្ធស្អាតស្អំ
- មានវិញ្ញាបនប័ត្រចុះបញ្ជីអាករលើតំលៃបន្ថែម ។

២- សមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ត្រូវមានលិខិតថ្កោលទោសដែលចេញដោយស្ថាប័នមានសមត្ថកិច្ច ដែលបញ្ជាក់ថា ពុំធ្លាប់មានទោស ។

៣- សមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ត្រូវមានប្រវត្តិអនុលោមភាពសារពើពន្ធស្អាតស្អំ

៤- សមាជិកក្រុមប្រឹក្សាភិបាលភាគច្រើនត្រូវមានសញ្ជាតិកម្ពុជា ឬជានិវេសនជនដែលមានលំនៅដ្ឋាននៅកម្ពុជា

៥- យ៉ាងហោចណាស់និយោជិកមួយរូបរបស់ក្រុមហ៊ុនត្រូវជាជើងសារគយមានមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ស្របតាមបញ្ញត្តិប្រការ ៥ នៃ ប្រកាសនេះ ។

**ប្រការ ៧ .-**

ទីចាត់ការគយ និងរដ្ឋាករ ត្រូវកំណត់មុខវិជ្ជាវិញ្ញាសាប្រឡងដែលពាក់ព័ន្ធនឹងវិជ្ជាជីវៈជើងសារគយ និងអាចរៀបចំវគ្គហ្វឹកហ្វឺនសម្រាប់បុគ្គលទាំងឡាយណាដែលមានបំណងប្រឡងជាជើងសារគយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

**ប្រការ ៨ .-**

ទីចាត់ការគេយ និងរង្វាករត្រូវរៀបចំការប្រឡងជ្រើសរើសជើងសារគេយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់យ៉ាងតិចមួយដងជារៀងរាល់ឆ្នាំ និងត្រូវជូនដំណឹងជាសាធារណៈអំពី កាលបរិច្ឆេទ ទីកន្លែង និងលក្ខខណ្ឌនានានៃការប្រឡងនេះ យ៉ាងតិច ហុកសិប (៦០) ថ្ងៃ មុនកាលបរិច្ឆេទនៃការប្រឡង ។

**ប្រការ ៩ .-**

អាជ្ញាប័ណ្ណជើងសារគេយត្រូវចេញសម្រាប់រូបវន្តបុគ្គលម្នាក់ៗដែលត្រូវបានកំណត់ថា ជាជើងសារគេយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។ និតិបុគ្គលមួយនឹងអាចទទួលបានអាជ្ញាប័ណ្ណជើងសារគេយ ប្រសិនបើនិយោជិកម្នាក់យ៉ាងតិចបំផុតរបស់ក្រុមហ៊ុនជាជើងសារគេយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

**ប្រការ ១០ .-**

អាជ្ញាប័ណ្ណជើងសារគេយត្រូវកំណត់នូវការិយាល័យគយដែលជើងសារគេយនោះត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការ និងលក្ខខណ្ឌចាំបាច់ជាកាតព្វកិច្ចនានារបស់ជើងសារគេយ ។ អាជ្ញាប័ណ្ណនេះត្រូវផ្តល់ជូនសម្រាប់រយៈពេល ពីរ (២)ឆ្នាំ ។

**ប្រការ ១១ .-**

ពាក្យសុំអាជ្ញាប័ណ្ណអាចត្រូវបានបដិសេធ ប្រសិនបើអ្នកស្នើសុំមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។ ក្រោយពេលទទួលបាននូវសេចក្តីជូនដំណឹងពីការបដិសេធ អ្នកស្នើសុំអាចតវ៉ាទៅរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីសុំពិនិត្យឡើងវិញនូវសេចក្តីសម្រេចបដិសេធនោះ ដោយបញ្ជាក់នូវសំអាងបន្ថែមនានា ។

**ប្រការ ១២ .-**

តាមសំណើរបស់នាយកទីចាត់ការគេយ និងរង្វាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចលុបចោល ឬព្យួរ នូវអាជ្ញាប័ណ្ណជើងសារគេយ ប្រសិនបើជើងសារគេយបាន ៖

- ខកខានមិនអនុវត្តតាមប្រកាសនេះ ។
- ល្មើសនឹងបញ្ញត្តិនានា នៃច្បាប់ស្តីពីគយ ឬបទបញ្ញត្តិនានាពាក់ព័ន្ធទៅនឹង /

ការនាំចូល ឬការនាំចេញទំនិញ ។

- កេងបន្ទំលើស្ថាប័នរដ្ឋ ឬអតិថិជនរបស់ខ្លួន ។
- ជាប់បំណុលមិនអាចសងរួច ឬក្ស័យធន ។
- ចូលរួមក្នុងការប្រព្រឹត្តអំពើមិនស្មោះត្រង់ណាមួយ នៅពេលធ្វើធុរកិច្ច ។
- ឈប់ធ្វើធុរកិច្ចជាជើងសារគយ ឬមិនបានបំពេញឱ្យបានត្រឹមត្រូវនូវភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនជាជើងសារគយ ។
- លែងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមបញ្ញត្តិនានានៃប្រកាសនេះ ។

មុនពេលលុបចោល ឬព្យួរអាជ្ញាប័ណ្ណ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬបុគ្គលដែលទទួលសិទ្ធិតំណាង ត្រូវជូនដំណឹងដល់ជើងសារគយ ជាមុន សាមសិប (៣០) ថ្ងៃ អំពីលទ្ធភាពនៃការលុបចោល ឬការព្យួរអាជ្ញាប័ណ្ណជើងសារគយ ដោយបញ្ជាក់នូវមូលហេតុនានានៃការលុបចោល ឬព្យួរអាជ្ញាប័ណ្ណនេះ ព្រមទាំងត្រូវផ្តល់ឱកាសដល់ជើងសារគយដើម្បីឆ្លើយតប ឬធ្វើការពន្យល់បង្ហាញនូវហេតុផលនានាពាក់ព័ន្ធនឹងករណីនេះ ។

**ប្រការ ១៣ .-**

ជើងសារគយ ដែលទទួលបានអាជ្ញាប័ណ្ណ ត្រូវបង់កម្រៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ ចំនួន ពីរលានរៀល (២.០០០.០០០) រៀល ដល់ទីចាត់ការគយ និងរដ្ឋាករ ។ កម្រៃអាជ្ញាប័ណ្ណនេះមិនត្រូវបានបង្វិលសងវិញឡើយ ។

**ប្រការ ១៤ .-**

ពាក្យសុំធ្វើអាជ្ញាប័ណ្ណជាថ្មីឡើងវិញត្រូវដាក់ជូនទីចាត់ការគយ និងរដ្ឋាករ យ៉ាងតិច សាមសិប ( ៣០ ) ថ្ងៃ មុនពេលអស់សុពលភាពនៃអាជ្ញាប័ណ្ណចាស់ ។ ការដាក់ពាក្យសុំធ្វើអាជ្ញាប័ណ្ណជាថ្មីឡើងវិញ ត្រូវដាក់ស្នើសុំតាមទម្រង់ និងភ្ជាប់មកជាមួយនូវឯកសារនានាស្របតាមបញ្ញត្តិប្រការ ៤ នៃប្រកាសនេះ និងត្រូវទទួលការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ១៥.-**

មុនពេលចាប់ផ្តើមប្រតិបត្តិការ ជើងសារគយដែលទទួលបានអាជ្ញាប័ណ្ណ ត្រូវតម្កល់និមុត្តិធានានៅទីចាត់ការគយ និងរដ្ឋាករឱ្យបានគ្រប់គ្រាន់ ដើម្បីធានាបាន

នូវពន្ធ អាករ បន្ទុក និងកម្រៃផ្សេងៗ ដែលត្រូវបង់នៅពេលណាមួយសម្រាប់ប្រតិបត្តិការបំពេញបែបបទបញ្ចេញទំនិញពីគយ ។

ទម្រង់ និងចំនួនទឹកប្រាក់នៃនិមុត្តិធានា ត្រូវកំណត់ដោយនាយកទីចាត់ការគយ និងរដ្ឋាករ ស្របតាមបញ្ញត្តិនៃប្រកាសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីនិមុត្តិធានា ។

**ប្រការ ១៦ .-**

ពាក្យសុំអាជ្ញាប័ណ្ណជើងសារគយថ្មីត្រូវដាក់ស្នើសុំនៅពេលមានការផ្លាស់ប្ដូរកម្មសិទ្ធិករ ដោយមិនគិតដល់ការផ្លាស់ប្ដូរនូវនាមករណ៍ក្រុមហ៊ុនឡើយ ។

ជើងសារគយដែលមានអាជ្ញាប័ណ្ណ ត្រូវជូនដំណឹងជាលាយល័ក្ខអក្សរ ដល់នាយកទីចាត់ការគយ និងរដ្ឋាករ អំពីសំណើផ្លាស់ប្ដូរនេះ ហើយត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណ ព្រមទាំងផ្ដល់នូវឯកសារនានា និងត្រូវដំណើរការដូចគ្នានឹងការដាក់ពាក្យសុំអាជ្ញាប័ណ្ណជើងសារគយជាថ្មីឡើងវិញស្របតាមបញ្ញត្តិនៃប្រកាសនេះ ។

**ប្រការ ១៧ .-**

ការបដិសេធ ឬការដកមកវិញនូវការអនុញ្ញាតជាបណ្ដោះអាសន្ន ឬជាអចិន្ត្រៃយ៍នូវអាជ្ញាប័ណ្ណជើងសារគយពុំត្រូវបានផ្ដល់នូវសំណង ឬជម្ងឺចិត្តអ្វីឡើយ។

**ប្រការ ១៨ .-**

ជើងសារគយត្រូវផ្ដល់ដល់មន្ត្រីគយមានសមត្ថកិច្ច នូវលិខិតពីអ្នកនាំចូល អ្នកនាំចេញ ឬម្ចាស់ទំនិញ ដែលអនុញ្ញាតឱ្យខ្លួនធ្វើបែបបទបញ្ចេញទំនិញពីគយក្នុងនាមពួកគេ ។ លិខិតនេះត្រូវបញ្ជាក់នូវរយៈពេល និងទីកន្លែងដែលត្រូវធ្វើបែបបទបញ្ចេញទំនិញពីគយ និងបញ្ជាក់នូវលក្ខខណ្ឌដទៃទៀតតាមការកំណត់របស់ទីចាត់ការគយ និងរដ្ឋាករ ។

រូបវន្តបុគ្គលជាជើងសារគយ ដែលជានិយោជិកនៃនីតិបុគ្គលជើងសារគយត្រូវផ្ដល់ជូនរដ្ឋបាលគយនូវការអនុញ្ញាតជាលាយល័ក្ខអក្សរ និងគម្រូហត្ថលេខាពីសាមីក្រុមហ៊ុន ។

**ប្រការ ១៩ .-**

នីតិបុគ្គលជើងសារគយត្រូវ ៖

- ធ្វើធុរកិច្ចជាជើងសារគយតែតាមទីកន្លែងដែលមានកំណត់ក្នុងអាជ្ញាប័ណ្ណ។

-មានរូបវន្តបុគ្គលជើងសារគយជាតំណាង ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅតាមការិយាល័យគយនីមួយៗដែលត្រូវធ្វើធុរកិច្ច ។ បុគ្គលនេះត្រូវបង្ហាញនៅតាមការិយាល័យគយពាក់ព័ន្ធនូវប័ណ្ណផ្លាកឈ្មោះ និងអាជ្ញាប័ណ្ណ ឬ ច្បាប់ចម្លងនៃឯកសារទាំងនេះ ។

- ជូនដំណឹងជាបន្ទាន់ដល់នាយកទីចាត់ការគយ និងរដ្ឋាករ អំពីការផ្លាស់ប្តូរណាមួយពាក់ព័ន្ធនឹង អាស័យដ្ឋាន នាមករណ៍ អ្នកគ្រប់គ្រង ម្ចាស់កម្មសិទ្ធិ ឬរូបវន្តបុគ្គលជើងសារគយជាតំណាងរបស់ក្រុមហ៊ុន ។

- ផ្តល់ជូនអ្នកនាំចូល ឬអ្នកនាំចេញ នូវច្បាប់ចម្លងនៃប្រតិវេទន៍គយ និងឯកសារដែលពាក់ព័ន្ធនឹងចម្លងការនីមួយ ៗ ។

**ប្រការ ២០ .-**

ជើងសារគយត្រូវរក្សាទុក ៖

- កំណត់ត្រា និងសៀវភៅគណនេយ្យទាំងអស់ដែលចង្អុលបង្ហាញនូវរាល់កិច្ចការជំនួញដែលត្រូវធ្វើឡើងរាល់ពេលបំពេញធុរកិច្ចជាជើងសារគយ ។

- ច្បាប់ចម្លងប្រតិវេទន៍គយនីមួយ ៗ និងឯកសារយោងទាំងអស់ ។

- ច្បាប់ចម្លងនៃលិខិតឆ្លើយឆ្លង ប័ណ្ណ បញ្ជីគណនេយ្យ របាយការណ៍ និងលិខិតស្នាមផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងចម្លងការធុរកិច្ចជាជើងសារគយ ។

ជើងសារគយ ត្រូវតែរក្សាទុកនូវសំណុំឯកសារដូចបានរៀបរាប់ខាងលើនៅទីកន្លែងធុរកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់រយៈពេល ដប់ (១០) ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជិកាប្រតិវេទន៍គយ ឬ ចាប់ពីចុងឆ្នាំដែលសំណុំឯកសារទាំងនេះបានធ្វើឡើង ឬទទួលបាន ។ សំណុំឯកសារទាំងនេះត្រូវរក្សាទុកតាមរបៀប និងលក្ខណៈដែលអាចឱ្យមន្ត្រីគយធ្វើសវនកម្ម ឬផ្ទៀងផ្ទាត់ព័ត៌មានបាន ។

**ប្រការ ២១ .-**

ជើងសារគយត្រូវទទួលខុសត្រូវចំពោះប្រតិបត្តិការដែលខ្លួនគ្រប់គ្រង ។ ជើងសារគយដែលបានប្រព្រឹត្តបទល្មើសនានា ដូចមានចែងក្នុងបញ្ញត្តិនៃច្បាប់ស្តីពី

គយ និងច្បាប់ផ្សេងៗទៀត ត្រូវទទួលរងនូវទោសទណ្ឌ តាមច្បាប់ និងបទបញ្ញត្តិនានាជាធរមាន ។

ក្នុងករណីដែលអ្នកនាំចូល អ្នកនាំចេញ ឬម្ចាស់ទំនិញមិនត្រូវបានរកឃើញ ភ្នាក់ងារជើងសារគយត្រូវទទួលខុសត្រូវចំពោះពន្ធ អាករ បន្ទុក និងកម្រៃផ្សេងៗ តាមច្បាប់ និងបទបញ្ញត្តិនានាជាធរមាន ។

**ប្រការ ២២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ២៣ .-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតត្រូវចាត់ចែងអនុវត្តតាមខ្លឹមសារប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ...
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីជូនជ្រាប "
- ដូចប្រការ ២៣
- សភាពាណិជ្ជកម្មកម្ពុជា " ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ